ភ្នំពេញ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# កិច្ចប្រជុំបូកសរុប លទ្ធផលប្រមូលចំណូលពន្ធ ប្រចាំខែមករា ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានពន្ធដារ




*© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ*

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុប លទ្ធផលគ្រប់គ្រងប្រមូលចំណូលប្រចាំ ខែមករា ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាព របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមានចូលរួម របស់ឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ ទាំងអស់ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល និងជាប្រធានអង្គប្រជុំ បានសម្តែងនូវ កិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានឯកឧត្តមអគ្គនាយករង លោក-លោកស្រី មន្ត្រីរាជការពន្ធដារទាំងអស់ ដែលបានចូលរួមក្នុងកិច្ចប្រជុំនាព្រឹកនេះ និងសូមសម្តែងនូវការអរគុណ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និង មន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងប្រមូលចំណូលពន្ធ រហូតសម្រេចបានលទ្ធផលគួរជាទីមោទនៈ។

ជាលទ្ធផល ក្នុងខែមករា ឆ្នាំ២០១៧ អគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ប្រមូលបានចំណូលពន្ធ-អាករគ្រប់ប្រភេទ និង ផ្ញើបែបបទសលាកបត្របង់ចូលថវិកាជាតិបានចំនួន ៩៨២ ៧៤៧,៧៨ លានរៀល (ប្រមាណជា ២៤៥,៦៩ លានដុល្លារ)។

ក្នុងគោលដៅបង្កើនផលិតភាព ក៏ដូចជាប្រសិទ្ធភាពការងារប្រមូលចំណូលពន្ធ ព្រមទាំងបន្តជំរុញអនុវត្តនូវផែនការសកម្មភាព និងកម្មវិធីកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងជាប្រធានអង្គប្រជុំ បានផ្តល់នូវអនុសាសន៍ណែនាំដល់អង្គភាពក្រោមឱវាទពន្ធដារ ដូចខាងក្រោម ÷

- បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាល និងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

- ពង្រឹងការដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំជាពិសេស ការប្រកាសបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦ តាមរយៈការពិនិត្យតាមដានជាប្រចាំ ចំពោះការបង់ប្រាក់ពន្ធ, ការរំឭកសហគ្រាស ដែលមិនមកដាក់លិខិតប្រកាសបង់ប្រាក់ពន្ធ, ការបង្កើនការពិនិត្យផ្ទៀងផ្ទាត់វិក្កយបត្រអាករ (VAT Cross Checking), ការត្រួតពិនិត្យលើវិធានការប្រើប្រាស់វិក្កយបត្រ

- ពង្រឹងការគ្រប់គ្រងប្រមូលអាករពិសេស តាមរយៈការពង្រឹងកិច្ចសហការជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំបោះពុម្ពសន្លឹកតែមប្រើអាករថ្មី ដែលមានលក្ខណៈស្របតាមបច្ចេកវិទ្យាខ្ពស់ និងប្រកបដោយសុវត្ថិភាព ងាយស្រួលក្នុងការគ្រប់គ្រងតាមដាន និងមិនអាចក្លែងបន្លំបាន

- ពង្រឹងការប្រមូលពន្ធប្រថាប់ត្រា លើការផ្ទេរកម្មសិទ្ធិ និងសិទ្ធិកាន់កាប់អចលនទ្រព្យ ព្រមទាំងពន្ធលើអចលន-ទ្រព្យ តាមរយៈការធ្វើបច្ចុប្បន្នភាពអចលនទ្រព្យទូទាំងប្រទេស

- ពង្រឹងការគ្រប់គ្រងប្រមូលពន្ធលើសហគ្រាសក្នុងវិស័យទូរគមនាគមន៍ វិស័យសំណង់ និងវិស័យដឹកជញ្ជូន

- បន្តនីតិវិធី នៃការចុះអង្កេតស្រាវជ្រាវសហគ្រាសតាមដងផ្លូវ (Street Survey) ដើម្បីឱ្យសហគ្រាសដែលមិនបានចុះបញ្ជីត្រឹមត្រូវ ឬលាក់ខ្លួនមិនព្រមមកចុះបញ្ជីពន្ធដារ នៅក្នុងខណ្ឌនានានៃរាជធានីភ្នំពេញ ឱ្យបានមកចុះបញ្ជីពន្ធដារ បានគ្រប់ៗគ្នា

- ពង្រឹង និង បង្កើនប្រសិទ្ធភាពគ្រប់គ្រងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ តាមរយៈការចុះត្រួតពិនិត្យការអនុវត្តបង់ពន្ធប្រភេទនេះ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស

- ពង្រឹងអភិបាលកិច្ចល្អរបស់រដ្ឋបាលសារពើពន្ធ តាមរយៈការធ្វើកំណែទម្រង់រចនាសម្ព័ន្ធការងារ និងប្រព័ន្ធការងារ ការពង្រឹងមុខងារភារកិច្ច របស់អង្គភាពក្រោមឱវាទទាំងអស់ ដើម្បីរៀបចំក្របខ័ណ្ឌប្រព័ន្ធការងារមួយ ដែលមានលក្ខណៈស៊ីសង្វាក់ប្រទាក់ក្រឡាគ្នា និងជួយជំរុញបង្កើនប្រសិទ្ធភាព និងផលិតភាពការងាររបស់អគ្គនាយកដ្ឋានពន្ធដារ

- បន្តលើកកម្ពស់ និងបញ្ជ្រាបវប្បធម៌នៃការបង់ពន្ធឱ្យបានជ្រួតជ្រាបកាន់តែប្រសើរថែមទៀត ជាពិសេសការអនុវត្តច្បាប់



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ស្ដីពីសារពើពន្ធ នៅក្នុងចំណោមធុរជនគ្រប់មជ្ឈដ្ឋាន តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពីប្រព័ន្ធពន្ធដារកម្ពុជា

- បន្តអប់រំណែនាំ ពង្រឹងការអនុវត្តច្បាប់ និងសមត្ថភាពមន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ ពង្រឹងអភិបាលកិច្ចល្អរបស់រដ្ឋបាលសារពើពន្ធ ជាពិសេសការកែប្រែផ្នត់គំនិត (Mindset) របស់មន្ត្រីរាជការពន្ធដារគ្រប់រូប ឲ្យយកចិត្តទុកដាក់អនុវត្តការងារប្រកបដោយការទទួលខុសត្រូវខ្ពស់ ដោយឈរលើមនសិការវិជ្ជាជីវៈ និង ស្មារតីតម្កល់ផលប្រយោជន៍ជាតិជាចម្បង ដោយចូលរួមអនុវត្តព្រមៗគ្នានូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំដៅធ្វើយ៉ាងណាធានាបាននូវប្រសិទ្ធភាព នៃការប្រមូលចំណូលពន្ធដោយផ្អែកលើអភិក្រម "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាលជម្ងឺ" ដែលបានដាក់ចេញដោយ សម្ដេចតេជោនាយករដ្ឋមន្ត្រី និងអភិក្រមការងារទាំងបួន ដែលបានដាក់ចេញដោយឯកឧត្តមទេសរដ្ឋមន្ត្រី។

ជាទីបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រធានអង្គប្រជុំបានវាយតម្លៃខ្ពស់ និងថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំគ្រប់អង្គភាព ក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដែលបាន និងកំពុងចូលរួមយ៉ាងសកម្មក្នុងការខិតខំ ប្រឹងប្រែងប្រមូលចំណូលរហូតទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ដែលនេះគឺជាជោគជ័យរួមរបស់អគ្គនាយកដ្ឋានពន្ធដារ ព្រោះថាប្រសិនបើមិនមានការចូលរួមពីគ្រប់អង្គភាពពាក់ព័ន្ធ លទ្ធផលប្រមូលចំណូលពន្ធនេះ នឹងមិនអាចសម្រេចទៅប្រកបដោយលទ្ធផលត្រចះត្រចង់បែបនេះបានឡើយ៕




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ